# របាយការណ៍ប្រចាំខែ មករា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរុំា និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅ កម្រិតរដ្ឋបាលថ្នាក់មន្ទីរ មានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- ថ្ងៃទី២៥ ខែធ្នូ មន្ត្រីការិយាល័យ ០១ រូប ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការ ឃុំ/សង្កាត់ ថ្នាក់ក្រុង/ស្រុក នៅសាលាស្រុក នៅសាលាស្រុកចុងកាល់
- ថ្ងៃទី២៥ ខែធ្នូ មន្ត្រីការិយាល័យ ០២ រូប ចូលរួមសិក្ខាសាលាបូកសរុបសមិទ្ធិផលការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ឆ្នាំ២០១៤ និងកិច្ចសហប្រតិបត្តិការឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ
- ថ្ងៃទី២៦ ខែធ្នូ មន្ត្រីការិយាល័យ ០១ រូប ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការ ឃុំ/សង្កាត់ ថ្នាក់ក្រុង/ស្រុក នៅសាលាស្រុកបន្ទាយអំពិល
- ថ្ងៃទី២៨ ខែធ្នូ មន្ត្រីការិយាល័យ ០១ រូប ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារ វត្តបុរីប្រាសាទជ័យ នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ
- ថ្ងៃទី៣០ ខែធ្នូ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យ ០១រូប ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការតែងតាំងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ និងការត្រៀមអនុវត្តរបៀបនៃការចុះលេខលិខិតថ្មីសម្រាប់ឆ្នាំ២០១៥ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី៣០ ខែធ្នូ ថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីចែកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅស្រុកត្រពាំងប្រាសាទក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅស្រុកត្រពាំងប្រាសាទ

- ថ្ងៃទី៣១ ខែធ្នូ មន្ត្រីការិយាល័យ ០១ រូប ចូលរួមប្រជុំស្តីពីការឆ្លើយតបវិធានការវិន័យរដ្ឋបាល និងកែកំហុសឆ្គងនៃការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ឆ្នាំ២០១៣ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ី ប្រាសិទ្ធ** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៦ ខែមករា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធនឹងការស្ថាបនាផ្លូវច្រកជប់គគីរ ក្រោមអធិបតីភាព **ឯកឧត្តម វ៉ាត ប៉ារ៉ានីន** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១១ ខែមករា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីដង្ហែព្រះសពព្រះគ្រូឧត្តរវាសី យង់ តិក អតីតព្រះមេគុណខេត្តឧត្តរមានជ័យ នៅរង្វង់មូលព្រះបាទជ័យវរ្ម័នទី ៧ ដង្ហែរមកកាន់វត្តប្រាសាទរាជា ដាក់តំកល់ លើព្រះមេរុ
- ថ្ងៃទី១២ ខែមករា លោកប្រធានមន្ទីរ ចូលរួមពិធីប្រកាសតែងតាំង ប្រគល់ភារកិច្ច និងផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ក្រោមអធិបតីភាព **ឯកឧត្តម យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ និង **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១២ ខែមករា លោកប្រធានមន្ទីរ ចូលរួមក្នុងពិធីសាងសង់ផ្ទះជូនដល់គ្រួសារចាស់ជរាទីទ័លក្រ នៅភូមិអូរគ្រោច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ
- ថ្ងៃទី១៣ ខែមករា មន្ត្រីការិយាល័យ ០២ រូប ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញការអនុវត្តកម្មវិធីឆ្នាំ ២០១៤ និងការលើកផែនការឆ្នាំ ២០១៥ នៅខេត្តបាត់ដំបង
- ថ្ងៃទី១៥ ខែមករា លោកប្រធានមន្ទីរ ចូលរួមកម្មពិធីបុណ្យបូជាព្រះសព ព្រះគ្រូ ឧត្តរវា សី យង់ តិក ក្រោមអធិបតីភាពសម្តេចព្រះសង្ឃរាជាធិបតី **ទេព្យ វង្ស** សម្តេចសង្ឃរាជា នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តប្រាសាទសំរោងរាជា
- ថ្ងៃទី១៥ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមប្រជុំសាមញ្ញលើកទី ៨ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី ២ ក្រោមអធិបតីភាព **ឯកឧត្តម យិម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១៥ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តម ស៊ីប្រាសិទ្ធិ** អភិបាលរងនៃគណៈអភិបាលខេត្ត នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១៥ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមប្រជុំដោះស្រាយការរៀបចំសណ្តាប់ធ្នាប់ និងការកែលម្អសោភ័ណ្ឌភាពច្រកទ្វារអន្តរជាតិជាំ និងការផ្លាស់ប្តូរទីតាំងធ្វើអាជីវកម្មរបស់អាជីវករ ក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅផ្សារផលសាម៉ន ស្រុកអន្លង់វែង

- ថ្ងៃទី១៦ ខែមករា លោកប្រធានមន្ទីរ ចូលរួមប្រជុំពាក់ព័ន្ធអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ស្តីពីការណែនាំឱ្យកែលម្អចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី១៩-២៣ ខែមករា មន្ត្រីការិយាល័យ ០៤ រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញគ្រប់គ្រងស្ថាប័នប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងទំនាស់ និងដំណោះស្រាយ និងការគ្រប់គ្រងប្រសិទ្ធភាពការងារ នៅសណ្ឋាគារឈឿនប្រាក់កប ខេត្តឧត្តរមានជ័យ និង
- ថ្ងៃទី២៣ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមសិក្ខាសាលា ស្តីពីការបង្ហាញលទ្ធផលវាយតម្លៃបញ្ចប់គម្រោង នៅសណ្ឋាគារ Green palace រាជធានីភ្នំពេញ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារថែទាំសុខភាពជនបទ

- ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៤ មន្ត្រីការិយាល័យ ០១ រូប ចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការលើកកម្ពស់អនាម័យជនបទតាមរយៈវិទ្យុខេត្ត នៅសណ្ឋាគារអាស៊ី ខេត្តកំពង់ឆ្នាំង។ កិច្ចប្រជុំនេះ រៀបចំដោយនាយកដ្ឋានថែទាំសុខភាពជនបទ និងមានអ្នកចូលរួមសរុបចំនួន ២៧ នាក់ ស្ត្រី ០៨ នាក់។ កិច្ចប្រជុំបានលើកយកប្រធានបទមកពិភាក្សាមានដូចជា÷
  - ជំរុញការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ
  - ផលលំបាកនៃការគ្មានបង្គន់ប្រើប្រាស់
  - អនាម័យបរិស្ថាន និង
  - ទឹកស្អាត ។
- ថ្ងៃទី០១-០៥ ខែមករា ចុះសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ មានភូមិគោលដៅសរុប ៤៣ ភូមិ ០៥ ឃុំ និង ០២ ស្រុក និងមានអ្នកចូលរួមសរុបចំនួន ១១៩ នាក់ ស្ត្រី ១៨នាក់។
- ថ្ងៃទី០១-១៨ ខែមករា រៀបចំកម្មវិធីអប់រំលើកកម្ពស់អនាម័យតាមរយៈវិទ្យុ (កម្មវិធីសំនួរ-ចម្លើយ និងកិច្ចពិភាក្សាតុមូល) សម្របសម្រួលដោយស្ថានីយ៍វិទ្យុ គីរីដងរែក FM90.25 MHz
- ថ្ងៃទី១០-១១ ខែមករា ចុះត្រួតពិនិត្យការងារសាងសង់បង្គន់អនាម័យនៅតាមភូមិគោលដៅចំនួន ១២ ភូមិ ស្ថិតនៅឃុំចុងកាល់ ឃុំពង្រ ស្រុកចុងកាល់ និងឃុំបេង ស្រុកបន្ទាយអំពិល (គម្រោង របស់រាជរដ្ឋាភិបាលកម្ពុជា)
- ថ្ងៃទី១៣-១៤ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមកិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យឡើងវិញការអនុវត្តកម្មវិធីឆ្នាំ ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ របស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី ម៉េង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង និងមានអ្នកចូលរួមសរុបចំនួន ៤៥ នាក់ ស្ត្រី ០៧ នាក់ និង

- ចុះត្រួតពិនិត្យ និងវាយតម្លៃ ស្តីពីការប្រតិបត្តិអនាម័យរបស់សហគមន៍ នៅភូមិគោលដៅ ៤៣ ភូមិ ០៥ ឃុំ និង ០២ ស្រុក និងមានអ្នកចូលរួមសរុបចំនួន ១២១៤ នាក់ ស្ត្រី ៨៤២ នាក់។

**៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត**

ថ្ងៃទី០៦ ខែមករា មន្ត្រីការិយាល័យ ០១ រូប ចូលរួមប្រជុំ ស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

**៣.៣ ការងារជនជាតិដើមភាគតិច**

ចុះស្រង់ទិន្នន័យជនជាតិដើមភាគតិច និងអំបូរជនជាតិនានា ក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង។

**៣.៤ ការងារការិយាល័យក្រុង -ស្រុក**

- ចូលរួមធ្វើផែនការសមាហរណកម្មថ្នាក់ស្រុកចុងកាល់
- ចូលរួមប្រជុំវិសមញ្ញលើកទី ៧ អាណត្តិទី ២ របស់ក្រុមប្រឹក្សាស្រុកចុងកាល់
- ចុះជួយជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ០២ លើក លើកទី ០១ នៅភូមិអំពិល ឃុំពង្រ ស្រុកចុងកាល់
- ចូលរួមប្រជុំ ស្តីពីការចុះកិច្ចសន្យាគម្រោងផ្លូវក្រាលក្រួសក្រហមឆ្នាំ ២០១៤ នៅភូមិសុភាព ភូមិគោតព្រិច និងភូមិឱឡោក ក្នុងឃុំអំពិល ស្រុកបន្ទាយអំពិល
- ចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាស្រុកបន្ទាយអំពិល
- ចូលរួមធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក នៅសាលាស្រុកបន្ទាយអំពិល និង
- ចូលរួមប្រជុំវិសាមញ្ញលើកទី ៧ អាណត្តិទី ២ របស់ក្រុមប្រឹក្សាស្រុកបន្ទាយអំពិល ។

**៤. ទិសដៅការងារបន្ត**

- ចុះត្រួតពិនិត្យការងារសាងសង់បង្គន់អនាម័យ ១២ ភូមិ ស្ថិតនៅឃុំចុងកាល់ ឃុំពង្រ ស្រុកចុងកាល់ និងឃុំបេង ស្រុកបន្ទាយអំពិល
- ចូលរួមរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទ ជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ
- ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ ទៅលើភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ១០០%
- រៀបចំកិច្ចប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ៤៥ អណ្តូង និងស្រះសហគមន៍ ០១ កន្លែង នៅស្រុកបន្ទាយអំពិល និងស្រុកត្រពាំងប្រាសាទ

- ចុះសាងសង់ និងជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ៣៤ អណ្តូង និងអណ្តូងស្នប់លេខ៦ ចំនួន ១១ អណ្តូង នៅស្រុកត្រពាំងប្រាសាទ និងស្រុកបន្ទាយអំពិល
- ចុះសាងសង់ស្រះសហគមន៍ ០១ កន្លែង នៅស្រុកបន្ទាយអំពិល
- ចុះប្រមូលទិន្នន័យខ្សែផ្លូវសាងសង់ថ្មី និងសំណង់សិល្បៈការ (សារពើភ័ណ្ឌផ្លូវ) និង
- ចុះស្រង់ទិន្នន័យធនាគារគោ និងធនាគារស្រូវ នៅឃុំអំពិល ស្រុកបន្ទាយអំពិល ។